ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា


ខុទ្ទកាល័យរដ្ឋមន្ត្រី (ស.អ.យ)
ចូល ថ្ងៃទី ០១ ខែ ១១ ឆ្នាំ ០៦
លេខ ១៣៤៤



លេខ ៦២៧
ថ្ងៃទី ០១ ខែ ១១ ឆ្នាំ ២០០៦
បញ្ជូន


# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ


...គដ្ឋានសោធនអតីតយុទ្ធជន
លេខ ៧២០
ថ្ងៃទី ៧៩ ខែ ១១ ឆ្នាំ ២០០៦
បញ្ជូន


## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ ០៧ /នស/៩៤ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក. ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់លក្ខខណ្ឌនៃការចូលនិវត្តន៍តាមការកំណត់ ការចូលនិវត្តន៍មុនពេលកំណត់ និងលក្ខខណ្ឌនៃការទទួលរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ សំដៅអនុវត្តច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ និងច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២.-** ដើម្បីអនុវត្តអនុក្រឹត្យនេះ ពាក្យដូចខាងក្រោម ត្រូវកំណត់និយមន័យដូចតទៅ :

- របបសោធននិវត្តន៍ គឺជាគោលរបបគិតជាទឹកប្រាក់ ដែលរដ្ឋត្រូវផ្តល់អោយយោធិនម្នាក់ៗ ដែលបានបំពេញតាមលក្ខខណ្ឌចូលនិវត្តន៍ និងរយៈពេលបំរើការងារ ។
- របបបាត់បង់សមត្ថភាពការងារ គឺជាគោលរបបគិតជាទឹកប្រាក់ ដែលរដ្ឋត្រូវផ្តល់អោយយោធិនម្នាក់ៗ ផ្អែកតាមសកម្មភាពបំពេញការងាររបស់ខ្លួនកន្លងមក មានផលប៉ះពាល់សុខភាព ដោយមិនអាចបន្តការងារទៀតបាន ហើយត្រូវបានចាត់ចូលក្នុង ប្រភេទបាត់បង់សមត្ថភាពការងារ ។
- របបចេញពីជួរ គឺជាទឹកប្រាក់ដែលត្រូវផ្តល់អោយយោធិនណាដែលបានបញ្ចប់ភារកិច្ចជាយោធិនអាជីព ហើយមិនបានបំពេញគ្រប់លក្ខខណ្ឌចូលនិវត្តន៍ និងមិនត្រូវបានចាត់ចូលក្នុងប្រភេទបាត់បង់សមត្ថភាពការងារ ។

## ជំពូកទី២

## របបសោធននិវត្តន៍

**មាត្រា៣.-**

យោធិនអាជីព អាចចូលនិវត្តន៍បានតាមការកំណត់ លុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាងក្រោម÷

**ក-នាយទាហាន :**

| | | |
|---|---|---|
| ១-ថ្នាក់វរសេនីយ៍ឯក | និងវរនាវីឯកឡើងទៅ | នៅពេលដល់អាយុ ៦០ ឆ្នាំ |
| ២-ថ្នាក់វរសេនីយ៍ទោ | និងវរនាវីទោ | នៅពេលដល់អាយុ ៥៨ ឆ្នាំ |
| ៣-ថ្នាក់វរសេនីយ៍ត្រី | និងវរនាវីត្រី | នៅពេលដល់អាយុ ៥៥ ឆ្នាំ |
| ៤-ថ្នាក់អនុសេនីយ៍ឯក | និងអនុនាវីឯក | នៅពេលដល់អាយុ ៥៣ ឆ្នាំ |

| | | |
|---|---|---|
| ៥-ថ្នាក់អនុសេនីយ៍ទោ | និងអនុនាវីទោ | នៅពេលដល់អាយុ ៤៨ ឆ្នាំ |
| ៦-ថ្នាក់អនុសេនីយ៍ត្រី | និងអនុនាវីត្រី | នៅពេលដល់អាយុ ៤៦ ឆ្នាំ |
| ៧-ថ្នាក់នាយចំណង់ | និងនាយនាវីចំណង់ | នៅពេលដល់អាយុ ៤៣ ឆ្នាំ |

ខ-នាយទាហានរង :

| | | |
|---|---|---|
| ១-ថ្នាក់ព្រិន្ទបាលឯក | និងនាយចក្របាលឯក | នៅពេលដល់អាយុ ៤២ ឆ្នាំ |
| ២-ថ្នាក់ព្រិន្ទបាលទោ | និងនាយចក្របាលទោ | នៅពេលដល់អាយុ ៤១ ឆ្នាំ |
| ៣-ថ្នាក់ពលបាលឯក | និងចក្របាលឯក | នៅពេលដល់អាយុ ៤០ ឆ្នាំ |
| ៤-ថ្នាក់ពលបាលទោ | និងចក្របាលទោ | នៅពេលដល់អាយុ ៣៩ ឆ្នាំ |
| ៥-ថ្នាក់ពលបាលត្រី | និងចក្របាលត្រី | នៅពេលដល់អាយុ ៣៨ ឆ្នាំ |

**មាត្រា៤.-**

យោធិនអាជីពដែលចូលនិវត្តន៍បានតាមការកំណត់ ដូចមានចែងក្នុងជំពូកទី២ មាត្រា៣ នៃអនុក្រឹត្យនេះ អាចទទួលរបបសោធននិវត្តន៍បាន លុះត្រាតែបានបំពេញគ្រប់លក្ខខណ្ឌរយៈពេលបំរើការងារ ដូចមានចែងក្នុងមាត្រា២ថ្មី នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា៥.-**

យោធិនអាជីព អាចចូលនិវត្តន៍បានមុនពេលកំណត់ ដោយមិនគិតពីលក្ខខណ្ឌឋានន្តរសក្តិ មិនគិតពីលក្ខខណ្ឌអាយុ អាចទទួលរបបសោធននិវត្តន៍បាន លុះត្រាតែបានបំពេញគ្រប់លក្ខខណ្ឌរយៈពេលបំរើការងារ ដូចមានចែងក្នុងមាត្រា២ថ្មី ចំណុច ក (១-២) នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា៦.-**

យោធិនអាជីព ដែលមិនបានទទួលរបបសោធននិវត្តន៍ ជាយោធិនមានគ្រប់លក្ខខណ្ឌឋានន្តរសក្តិ មានគ្រប់លក្ខខណ្ឌអាយុ តែមិនបានបំពេញគ្រប់លក្ខខណ្ឌរយៈពេលបំរើការងារ ត្រូវទទួលបានរបបចេញពីជួរ ដោយទទួលប្រាក់ឧបត្ថម្ភផ្តាច់សរុបមួយ ស្មើនឹងបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួន គុណនឹងចំនួនឆ្នាំនៃរយៈពេលបំរើការងារ ប៉ុន្តែទឹកប្រាក់នេះ មិនត្រូវតិចជាង ៦ខែ នៃបៀវត្សសរុបចុងក្រោយរបស់សាមីខ្លួនឡើយ ។

**មាត្រា៧.-**

របៀបគិតរយៈពេលបំរើការងារ ព្រមទាំងកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព

របស់យោធិនម្នាក់ៗ ត្រូវបានកំណត់ដូចខាងក្រោម ÷

**១.របៀបគិតរយៈពេលបំរើការងារ :**

ការគិតរយៈពេលបំរើការងារ គឺបានគិតរួមទាំងរយៈពេលបំរើការងារគ្រប់របបសង្គម "បើមាន" និងរយៈពេលបំរើការងារស៊ីវិល និងកងយោធពលខេមរភូមិន្ទដោយ :

**ក-ត្រូវចាត់ទុកជារយៈពេលបំរើការងារ :**

ការចាត់ទុកជារយៈពេលបំរើការងារ គឺគិតចាប់តាំងពីមន្ត្រីរាជការ បុគ្គលិក កម្មកររដ្ឋ ដែលបានបញ្ចូលទៅក្នុងក្របខណ្ឌ "រដ្ឋពេញសិទ្ធិ" រួចក្រោយមក ចូលបំរើក្នុងកងយោធពលខេមរភូមិន្ទ ឬចាប់ពីពេល ចូលបំរើក្នុងកងយោធពលខេមរភូមិន្ទជាប់រហូត ដល់ពេលចូលនិវត្តន៍ ។ ស្ថានភាពនៃរយៈពេលបំរើការងារ ត្រូវបាន គិតដូចខាងក្រោម ÷

-រយៈពេលធ្វើរដ្ឋបាល ភូមិ ឃុំ សង្កាត់ ឬកងជីវពល ដែលមានប្រាក់ឧបត្ថម្ភ

-រយៈពេលមន្ត្រីរាជការ បុគ្គលិក កម្មកររដ្ឋ ធ្វើការតាមក្រសួង ស្ថាប័នរដ្ឋនានា ឬរយៈពេលទៅធ្វើកម្មសិក្សាក្នុង ឬក្រៅប្រទេស

-រយៈពេលមន្ត្រីរាជការ ធ្វើការងារក្រៅប្រទេស

-រយៈពេលបំរើការងារអតីតភាពតាមរបបសង្គម

-រយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ

-រយៈពេលជាប់មន្ទីរឃុំឃាំង ដោយគ្មានទោសកំហុស

-រយៈពេលដែលយោធិនស្ថិតក្នុងកិច្ចសន្យា ។

**ខ-មិនត្រូវចាត់ទុកជារយៈពេលបំរើការងារ :**

-គឺជារយៈពេល ដែលតម្រូវអោយមន្ត្រីរាជការ បុគ្គលិក កម្មកររដ្ឋ ធ្វើការសាកល្បង ។

**២.ការកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ដូចជា :**

តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវបានកំណត់ដូចខាងក្រោម ÷

**ក-តំបន់លំបាក :**

យោធិនបានបំពេញភារកិច្ចនៅតំបន់ដាច់ស្រយាល ឬកោះ តំបន់គ្រុនចាញ់ តំបន់ព្រៃភ្នំ លំបាកដោយអាកាសធាតុ ឬលំបាកដោយជីវភាពរស់នៅ និងសមរភូមិប្រយុទ្ធ ។

**ខ-ការងារគ្រោះថ្នាក់ :**

យោធិនជាអាកាសយានិក ទ័ពជំនាញឆ័ត្រយោង ទ័ពវិស្វកម្ម ជំនាញដោះមីន ទ័ពជំនាញ ផលិត ឬពិសោធន៍គ្រឿងផ្ទុះ ។

**គ-ការងារប៉ះពាល់សុខភាព :**

យោធិនជានាវិក ជាងផ្សារដែក ជាងជួសជុលគ្រឿងចក្រធុនធ្ងន់ បុគ្គលិកវ៉ាដា ជាងអគ្គិសនី

អ្នកធ្វើការងារនៅអាគារជម្ងឺឆ្លង អាគារថតឆ្លុះ និងមន្ទីរពិសោធន៍ មន្ទីរពេទ្យ ទ័ពជំនាញគីមីសាស្ត្រ ជំនាញកាំភ្លើងធំ អ្នកបើកបរគ្រឿងចក្រធុនធ្ងន់ ។

ដើម្បីអនុវត្តឱ្យបានល្អ និងមានប្រសិទ្ធភាពនោះ ក្រសួងការពារជាតិត្រូវធ្វើប្រកាស កំណត់លំអិតអំពីលក្ខខណ្ឌជាក់ស្តែង ។

**មាត្រា៨.-**

ប្រាក់សោធននិវត្តន៍រួមមាន បៀវត្សរ៍ឋានន្តរសក្តិ ត្រូវបានបូកបន្ថែមជាមួយប្រាក់ឧបត្ថម្ភលើបៀវត្សរ៍ឋានន្តរសក្តិ បូកប្រាក់ហូបប្រចាំខែ បូកប្រាក់បំណាច់មុខងារ "បើមាន" បូកប្រាក់បំណាច់តំបន់ "បើមាន" ។

**មាត្រា៩.-**

យោធិនអាជីព ដែលមានគ្រប់លក្ខខណ្ឌ ត្រូវបានទទួលរបបសោធននិវត្តន៍ជាប្រចាំខែ ដូចមានចែងក្នុង ជំពូកទី ១ មាត្រា ៥ និងមាត្រា ៦ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

ក្រៅពីទទួលរបបសោធននិវត្តន៍ប្រចាំខែ ដូចបានបញ្ជាក់ក្នុងវាក្យខណ្ឌខាងលើ ត្រូវបានទទួលរបបអ្នកនៅក្នុងបន្ទុកដែលរដ្ឋទទួលស្គាល់ ដូចនៅពេលបំរើការងារ ។

**មាត្រា១០.-**

យោធិនអាជីព មុនពេលចូលនិវត្តន៍ អាចអនុញ្ញាតឈប់សម្រាកច្បាប់ ដោយផ្អែកលើករណីចាំបាច់ ដើម្បីប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសារ ដូចមានចែងក្នុងជំពូកទី ១ មាត្រា ៦ ចំណុច ២ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

-ថ្នាក់ព្រិន្ទបាលឯកចុះ ត្រូវបានឈប់សម្រាក ៦ខែ

-ថ្នាក់នាយចំណង់ និងអនុសេនីយ៍ ត្រូវបានឈប់សម្រាក ៨ខែ

-ថ្នាក់វរសេនីយ៍ ត្រូវបានឈប់សម្រាក ១០ខែ

-ថ្នាក់ឧត្តមសេនីយ៍ ឬវីរជន ត្រូវបានឈប់សម្រាក ១២ខែ ។

នៅពេលឈប់សម្រាកច្បាប់ក្នុងប្រទេស ត្រូវបានទទួលប្រាក់ធ្វើដំណើរ ប្រាក់ហូបចុកតាមផ្លូវទាំងទៅ ទាំងមកតាមប្រកាសកំណត់របស់ក្រសួងការពារជាតិ ។

**មាត្រា១១.-**

យោធិនអាជីព ដែលមានវិន័យ គុណសម្បត្តិ សមត្ថភាព និងសុខភាពល្អ ឬជាអ្នកជំនាញឯកទេស ដែលដល់អាយុកំណត់ចូលនិវត្តន៍ អាចសុំបន្តបំរើការងារ ១ឆ្នាំម្តង១ ដោយមានការយល់ព្រម ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ មានសិទ្ធិដូចខាងក្រោម ÷

១-ទទួលបៀវត្សដូចក្នុងស្ថានភាពសកម្ម

២-រយៈពេលបំរើការងារបន្ត ត្រូវបានគិតក្នុងអតីតភាព ដើម្បីទទួលរបបសោធននិវត្តន៍អតិបរិមា ឬអប្បបរិមា

៣-រយៈពេលសុំបន្តការងារ មិនលើសពី ៥ឆ្នាំឡើយ ។

## ជំពូកទី៣

## របបសោធនបាត់បង់សមត្ថភាពការងារ

### មាត្រា១២.-

យោធិនអាជីព ដែលអាចទទួលរបបបាត់បង់សមត្ថភាពការងារបានជាប្រចាំខែ លុះត្រាតែបានបំពេញតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ២ មាត្រា ៩ និងមាត្រា ១២ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

អំពីរបៀបគិតរយៈពេលបំរើការងារ ព្រមទាំងការកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព គឺត្រូវអនុវត្តតាមការកំណត់ ដូចមានចែងក្នុងជំពូកទី ២ មាត្រា ៧ នៃអនុក្រឹត្យនេះ ។

### មាត្រា១៣.-

លក្ខខណ្ឌជាក់ស្តែងនៃការកំណត់ប្រភេទកំរិតថ្នាក់បាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីព ត្រូវបានកំណត់កំរិតជាបីថ្នាក់ ÷

**ក-កំរិតថ្នាក់ទី១ :**

គឺជាយោធិនអាជីព ដែលបានបំរើការងារ នាំអោយទ្រុឌទ្រោមទាំងស្រុងនៃសរីរាង្គកាយសំខាន់ៗ ។ ជនបាត់បង់សមត្ថភាពការងារ ពុំអាចធ្វើការងារបំរើខ្លួនឯងបាន និងតម្រូវអោយអ្នកដទៃជួយជាអចិន្ត្រៃយ៍ ។ យោធិននេះទទួលបានកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ លើសពី ៨០ភាគរយ ។

**ខ-កំរិតថ្នាក់ទី២ :**

គឺជាយោធិនអាជីព ដែលបានបំរើការងារ នាំអោយមានការទ្រុឌទ្រោមធ្ងន់ ឬស្រាលនៃមុខងារសំខាន់ៗរបស់សរីរាង្គកាយ ។ ជនបាត់បង់សមត្ថភាពការងារ អាចប្រកបការងារបាននៅក្នុងករណីពិសេស សាមីជនអាចធានាបានដោយខ្លួនឯងនូវសេចក្តីត្រូវការរបស់ខ្លួនមួយផ្នែកក្នុងជីវភាពប្រចាំថ្ងៃ ដោយមិនចាំបាច់ពឹងផ្អែកជំនួយអចិន្ត្រៃយ៍ពីអ្នកដទៃឡើយ ។ យោធិននេះទទួលបានកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ លើសពី ៦០ភាគរយ ។

**គ-កំរិតថ្នាក់ទី៣ :**

គឺជាយោធិនអាជីព ដែលអាចបំរើការងារបាននៅក្នុងករណីដែលបានកំណត់ ដោយមិនចាំបាច់មានអ្នកដទៃជួយនៅក្នុងជីវភាពប្រចាំថ្ងៃឡើយ ។ យោធិននេះ ទទួលបានកំរិតថ្នាក់បាត់បង់សមត្ថភាពការងារលើសពី ៤០ភាគរយ ។

លក្ខខណ្ឌលំអិតជាក់ស្តែង នៃការកំរិតលក្ខណៈបាត់បង់សមត្ថភាពការងារ របស់យោធិនអាជីពទាំងពីរភេទ តាមថ្នាក់នីមួយៗ ត្រូវបានកំណត់ដោយប្រកាសរួមអន្តរក្រសួង របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា១៤.-**

ប្រាក់សោធនបាត់បង់សមត្ថភាពការងារ រួមមាន បៀវត្សរ៍ឋានន្តរសក្តិ ត្រូវបានបូកបន្ថែមជាមួយប្រាក់ឧបត្ថម្ភលើបៀវត្សរ៍ឋានន្តរសក្តិ បូកប្រាក់ហូបប្រចាំខែ បូកប្រាក់បំណាច់មុខងារ "បើមាន" បូកប្រាក់បំណាច់តំបន់ "បើមាន" ។

**មាត្រា១៥.-**

យោធិនអាជីព ដែលអាចទទួលរបបសោធនបាត់បង់សមត្ថភាពការងារប្រចាំខែបាន លុះត្រាតែបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី២ មាត្រា១២ និងមាត្រា១៣ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

ក្រៅពីរបបដែលបានបញ្ជាក់ក្នុងវាក្យខណ្ឌខាងលើ យោធិនអាជីពទាំងពីរភេទ អាចទទួលបាននូវរបបអ្នកនៅក្នុងបន្ទុកដែលរដ្ឋទទួលស្គាល់ ដូចនៅពេលបំរើការងារ ។

**មាត្រា១៦.-**

យោធិនអាជីព ដែលមិនមានគ្រប់លក្ខខណ្ឌទទួលរបបសោធនបាត់បង់សមត្ថភាពការងារ ត្រូវទទួលបានរបបចេញពីជួរ ដូចមានចែងក្នុងជំពូកទី២ មាត្រា១១ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

## ជំពូកទី៤
## សមត្ថកិច្ចនៃការគ្រប់គ្រង និងបើករបបសោធននិវត្តន៍ និងរបបសោធនបាត់បង់សមត្ថភាពការងារ

**មាត្រា១៧.-**

សមត្ថកិច្ចនៃការសំរេចអោយបន្តការងារទៀត ឬសំរេចអោយចូលនិវត្តន៍បាន ដូចមានចែងក្នុងជំពូកទី ១ មាត្រា ៨ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពល

ខេមរភូមិន្ទ ព្រមទាំងអោយទទួលសោធនបាត់បង់សមត្ថភាពការងារ ឬអោយចេញពីជួរ ត្រូវបានកំណត់ដូចខាងក្រោម ÷

១- ដោយព្រះរាជក្រឹត្យ សម្រាប់យោធិនអាជីពថ្នាក់ឧត្តមសេនីយ៍ និងឧត្តមនាវី ។

២-ដោយអនុក្រឹត្យ សម្រាប់យោធិនអាជីពថ្នាក់វរសេនីយ៍ឯក និងវរនាវីឯក ។

៣- ដោយប្រកាសរបស់ក្រសួងការពារជាតិ សម្រាប់យោធិនអាជីពចាប់ពីថ្នាក់វរសេនីយ៍ទោ និងវរនាវីទោចុះ ។

ដើម្បីអនុវត្តឱ្យបានល្អនិងមានប្រសិទ្ធភាព ក្រសួងការពារជាតិត្រូវធ្វើប្រកាស កំណត់អំពីរបៀបគណនា ប្រាក់សោធននិវត្តន៍ ប្រាក់សោធនបាត់បង់សមត្ថភាពការងារ និងកំណត់អំពីគំរូបែបបទសំណុំលិខិត នៃការដាក់ឱ្យចូលនិវត្តន៍ ដាក់ឱ្យចូលបាត់បង់សមត្ថភាពការងារ និងដាក់ឱ្យចេញពីជួរ ព្រមទាំងគំរូបែបបទ នៃការស្នើសុំបន្តការងារ នៅពេលដល់អាយុចូលនិវត្តន៍ ។

## មាត្រា១៨.-

ជារៀងរាល់ឆ្នាំ ក្រសួងការពារជាតិត្រូវធ្វើបញ្ជីឈ្មោះ ភ្ជាប់ជាមួយតួលេខចំនួនទឹកប្រាក់យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពការងារ និងយោធិនចេញពីជួរ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបំរុងថវិកាបើកផ្តល់ប្រាក់សោធននិវត្តន៍ សោធនបាត់បង់ សមត្ថភាពការងារ និងចេញពីជួរ ។

ក្រសួងការពារជាតិ មានភារកិច្ចបើកប្រាក់ឧបត្ថម្ភមួយលើកជូនដល់និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងយោធិនចេញពីជួរ បន្ទាប់មកត្រូវផ្ទេរទៅអោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ក្រោយពីទទួលបាននិវត្តជន ជនបាត់បង់សមត្ថភាពការងារពីក្រសួងការពារជាតិរួចមក ការគ្រប់គ្រង ការបើកចែករបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ និងការបើករបបធានារ៉ាប់រងសង្គម សំរាប់គ្រួសារ ក្រោយមរណភាពរបស់និវត្តជន ឬជនបាត់បង់សមត្ថភាពការងារ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រហូតដល់ពេលបង្កើតបេឡាសោធន ។

## មាត្រា១៩.-

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធរមានសមត្ថកិច្ចពិនិត្យលទ្ធភាព ក្នុងការបណ្តុះបណ្តាល និងជួយរកការងារធ្វើអោយនិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងអតីតយោធិនចេញពីជួរ ដែលមានលទ្ធភាពធ្វើការងារទៀតបាន ផ្អែកតាមសំណើ និងជំនាញរបស់សាមីខ្លួន ។

## មាត្រា២០.-

យោធិនបាត់បង់សមត្ថភាពការងារ ដែលគ្មានទីបង្អែកដូចមានចែងក្នុងជំពូកទី ២មាត្រា ១៣ (ចំណុច២) នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ រដ្ឋទទួលបន្ទុកយកទៅស្នាក់នៅមជ្ឈមណ្ឌលរបស់រដ្ឋ ឬនិវត្តជនចាស់ជរារស់នៅតែលតោលគ្មានទីបង្អែក ក៏មានសិទ្ធិដូចជន

បាត់បង់សមត្ថភាពដែរ ។

ចំពោះប្រាក់សោធននិវត្តន៍ ឬសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ត្រូវកាត់យកស្មើនឹង ៥០ភាគរយ ដើម្បីធានាការហូបចុក បើសិនជាខ្វះខាត រដ្ឋបំពេញបន្ថែម ។ ចំពោះយោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី១ បើសិនទៅរស់នៅមជ្ឈមណ្ឌលរបស់រដ្ឋ ប្រាក់ឧបត្ថម្ភសំរាប់អ្នកជំនួយកិច្ចការក្នុងផ្ទះមិនបានបើកផ្តល់អោយឡើយ ។

**មាត្រា២១.-**

និវត្តជន ឬជនបាត់បង់សមត្ថភាពការងារ មានសិទ្ធិស្លៀកពាក់ឯកសណ្ឋានកងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងជំពូកទី ១ មាត្រ ៧ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ដើម្បីជាកិត្តិយសក្នុងពិធីបុណ្យជាតិផ្សេងៗ ។

ការបើកផ្តល់ឯកសណ្ឋានកងយោធពលខេមរភូមិន្ទនេះ ត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

**មាត្រា២២.-**

ក្រោយពេលនិវត្តជន ឬជនបាត់បង់សមត្ថភាពការងារទទួលមរណភាព គ្រួសារទាំងនេះ ត្រូវបានប្រាក់ឧបត្ថម្ភ ដូចមានចែងក្នុងជំពូកទី២ មាត្រា១៤ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា២៣.-**

អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងអនុក្រឹត្យលេខ ៣២ អនក្រ.បក. ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០០ ស្តីពីវិសោធនកម្មមាត្រា៤ ១៤ និង១៥ នៃអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមិនា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា២៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ២០០

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

ទៀ បាញ់

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា២៤
-ឯកសារ-កាលប្បវត្តិ

០០៦